**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខៈ៣៩
ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០០២
**សាលដីកា**
លេខៈ២៦០
ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៤

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅៈ

១-ឯកឧត្តម ............ ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ
២-លោក ................ ជាចៅក្រមរបាយការណ៍
៣-លោក ................ ជាចៅក្រម
៤-លោក ................. ជាចៅក្រម
៥-លោក ................. ជាចៅក្រម
៦-លោក ................ ជាចៅក្រម
៧-លោក ................ ជាចៅក្រម
៨-លោក ................ ជាចៅក្រម
៩-លោក ................។ ជាចៅក្រម

**ក្រឡាបញ្ជី**

-លោក .................

**តំណាងមហាអយ្យការ**

-លោក ............. ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ៦៩(ច) ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០១ នៃសំណុំរឿងរដ្ឋប្បវេណីលេខ២៤ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០១ របស់សាលា ឧទ្ធរណ៍រវាង :

ដើមចោទឈ្មោះ អផ(ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រី អាយុ៥២ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ ទីលំនៅសព្វថ្ងៃ ផ្ទះលេខ១៥EQA ផ្លូវបារាំង (កូលាបទី១ សង្កាត់ស្រះចក ខណ្ឌ ដូនពេញ ក្រុងភ្នំពេញ ។

ចុងចម្លើយឈ្មោះនណវ(ជាចុងបណ្តឹងសាទុក្ខ)ភេទស្រី អាយុ៥៤ឆ្នាំ ជាតិខ្មែរ មុខរបរលក់បារី ទីលំនៅសព្វថ្ងៃផ្ទះលេខ ៩២Eoz ផ្លូវលេខ១៣៦ សង្កាត់ផ្សារកណ្តាល២ ខណ្ឌ ដូនពេញ ក្រុងភ្នំពេញ។

**កម្មវត្ថុបណ្តឹងៈ** ប្តឹងសុំសិទ្ធិកាន់កាប់តូបលេខ១៤ (ផ្សារចាស់) .

បានឃើញបណ្តឹងសាទុក្ខលេខ៣៥៤ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០១ របស់ឈ្មោះអផប្តឹងមិនសុខចិត្តនិងសាលដីការដ្ឋប្បវេណីលេខ៦៩ (ច) ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៣៩ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០០២ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី១៣-២-១៩៩៨ របស់ឈ្មោះអផដើមចោទ ប្តឹងសុំសិទ្ធិ កាន់កាប់តូបលក់ដូបានរីលេខ ១៤ នៅផ្សារចាស់ ដោយសំអាងហេតុថាៈ ឈ្មោះសុខ អ៊ូច ជំពាក់ប្រាក់ខ្លួនចំនួន ១.៥០០ដុល្លាអាមេរិក ហើយ សុខ អ៊ូច បានសរសេរលិខិតប្រគល់តូបលេខ១៤ នៅផ្សារចាស់ឲ្យមកខ្លួនកាន់កាប់តាមលិខិតចុះថ្ងៃទី២៤-១០-១៩៩៥ ។ បន្ទាប់ពីបានទទួល

លិខិត បណ្ដាំនោះ ខ្លួនក៏ទៅទំនាក់ទំនងប្រធានផ្សារចាស់ តែតូបលក់បារីលេខ១៤ នោះ មានអ្នកផ្សេង កំពុងលក់បារីទៅវិញ។ខ្លួនសំណូមពរដល់តុលាការចេញដីកាសម្រេចជាប្រញាប់ ថ្វាកការលក់ដូរលើ តូបលក់បារីលេខ ១៤ មួយរយៈសិន ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ១២(ច) ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ១៩៩៩ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖

១-ទទួលពាក្យបណ្ដឹងចុះថ្ងៃទី១៣-២-៩៨ របស់ដើមចោទឈ្មោះអផទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទទួលស្គាល់ថា តូបលក់បារីលេខ១៤ នៅផ្សារចាស់ពិតជាកម្មសិទ្ធិរបស់ឈ្មោះសុខ អ៊ួច ត្រឹមត្រូវតាមច្បាប់ ។

៣-ទទួលស្គាល់ការប្រគល់តូបលក់បារីលេខ១៤ នៅផ្សារចាស់ពីឈ្មោះសុខ អ៊ួច ឱ្យទៅ ឈ្មោះអផទុកជាត្រឹមត្រូវតាមច្បាប់ ។

៤-បង្គាប់ឱ្យឈ្មោះគួន ណារី ប្រគល់តូបលក់បារីលេខ ១៤ នៅផ្សារចាស់ឱ្យទៅឈ្មោះអផចាប់ពីថ្ងៃដែលសាលក្រមនេះ ចូលជាស្ថាពរ ។

៥-បង្គាប់ឱ្យឈ្មោះគួន ណារី សងប្រាក់ប្រដាប់ក្ដីចំនួន ៧.០០០៛ ឱ្យទៅដើម ចោទវិញ បន្ទាប់ពីសាលក្រមនេះចូលជាស្ថាពរ ។ ប្រាក់ចំនួន ៧.០០០៛ នេះ ត្រូវបានកាត់យកពី ដើមចោទ ដែលបានបង់ទុកជាស្រេច ។

៦-សាលក្រមនេះ ជំនុំជំរះនិងប្រកាសជាសាធារណៈចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយឈ្មោះគួនណារី ហើយសម្រេចបើកផ្លូវបណ្ដឹងទាស់ និងបណ្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ១១(ច)ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ របស់ឈ្មោះគួន ណារី ប្ដឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ១២ (ច) ចុះថ្ងៃទី០៥-៤-១៩៩៩ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ០៦(ង) ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖

១-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី១០-៥-១៩៩៩ របស់ឈ្មោះគួន ណារី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ១២(ច) ចុះថ្ងៃទី០៥-០៤-១៩៩៩ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការ ។

៣-សម្រេចកាត់យកប្រាក់ប្រដាប់ក្ដី ជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០៛ គឺពន្ធចុះបញ្ជីក្ដី និងពន្ធហ្នឹង២៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ៥០០០៛ ចំណាយលើអាជ្ញាធរតុលាការ៥០០០៛ សរុប ១៣០០០៛ ។

៤-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្ដី ។

បើកផ្លូវប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលេខ៤៥ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០០ របស់ឈ្មោះគួន ណារី ប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ០៦(ង)ចុះថ្ងៃទី១១ខែមករា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៣៩ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០១ របស់តុលាការកំពូលដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ :

១-ទទួលបណ្ដឹងសាទុក្ខលេខ៤ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០០ របស់អ្នកស្រី គួន ណារី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ និងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ០៦(ង)ចុះថ្ងៃទី១១ខែមករា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ២៨០ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០០ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្ដីចំនួន១៥.០០០៛ ដែលអ្នកស្រីគួន ណារី បានបង់រួចហើយគឺ៖

-ពន្ធចុះបញ្ជីក្ដី និងពន្ធហ្នឹងចំនួន៤០០០៛ ប៉ុន្ដែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩.០០០រៀល . ហើយតម្រូវឱ្យអ្នកស្រីអផសងប្រាក់ ១៩.០០០៛ នេះទៅអ្នកស្រីខ្លួន ណារី វិញ ។

៥-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០១ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៦៩(ច) ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ :

១-ទទួលជំនុំជំរះសំណុំរឿងរដ្ឋប្បវេណីលេខ២៤ ចុះថ្ងៃទី២៤-៤-២០០១របស់សាលាឧទ្ធរណ៍ ដោយអំណាចសាលដីការដ្ឋប្បវេណីលេខ៣៨ ចុះថ្ងៃទី១៥-៣-២០០១ របស់ តុលាការកំពូល ។

២-ប្រគល់តូបទំនាស់លេខ១៤ នៅក្នុងផ្សារចាស់ឱ្យទៅឈ្មោះគួន ណារី កាន់កាប់តទៅ ។

៣-កាត់យកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០៛ គឺពន្ធចុះបញ្ជីក្ដី និងពន្ធហ្នឹង២៥៥១៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ ចំណាយលើកិច្ចដីកាកោះ៥.០០០៛ និងចំណាយលើអាជ្ញាធរតុលាការ៥.០០០៛ សរុប ១៣.០០០៛ និងបង្គាប់ឱ្យដើមចោទបង់ពន្ធ សមាមាត្រ១% លើថ្លៃតូបទំនាស់ ។

៤-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្ដី បើកផ្លូវប្ដឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលេខ៣៥៤ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០១ របស់ឈ្មោះអផប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៦៩(ច) ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

បានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា៖ សាលដីការដ្ឋប្បវេណីលេខ៦៩(ច) ចុះថ្ងៃទី០៨-១០-២០០១ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្ដីមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិនិត្យ និងសម្រេច ។

បានស្ដាប់ចម្លើយរបស់ឈ្មោះគួន ណារី នាពេលសវនាការថា ៖ ឈ្មោះសុខ អ៊ូច បានប្រគល់ប័ណ្ណតូបឱ្យខ្លួន ព្រោះគាត់ជំពាក់លុយខ្លួន ហើយឈ្មោះអផមិនសុខចិត្តប្ដឹងខ្លួន ។ សុខ អ៊ូច ជាប្ដីម៉ែអាមួយ គាត់មានកូន៣នាក់ គាត់លក់ផ្ទះបាត់ ហើយមិនដឹងទៅរស់នៅឯណាទេ។

-ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់ចម្លើយអ្នកស្រី គួន ណារី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**តុលាការកំពូល**

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ៣៥៤ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០១ របស់អ្នកស្រីអផធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា២២៦ នៃ ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលមានអានុភាពអនុវត្តលើរឿងរដ្ឋប្បវេណីផងដែរ ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេចប្រគល់តូបទំនាស់លេខ១៤ នៅក្នុងផ្សារចាស់ឱ្យអ្នកស្រីគួន ណារី តែម្នាក់ឯង ដោយផ្អែកលើលិខិតប្រគល់តូបចុះថ្ងៃទី១៤-៤-១៩៩៥ របស់លោកសុក អ៊ូច នោះជាការពុំត្រឹមត្រូវទេ ពីព្រោះអ្នកស្រីម៉ែអាមួយ ដែលជាប្រពន្ធលោកសុក អ៊ូច បានប្រគល់តូចទំនាស់ឱ្យអ្នកស្រីអផតាមលិខិតចុះថ្ងៃទី២៤-០១-១៩៩៥រួចហើយ ដូច្នេះឃើញថាលោកសុខ អ៊ូច និងអ្នកស្រីម៉ែអាមួយ ដែលជាប្តីប្រពន្ធមានជំពាក់បំណុលអ្នកស្រីអផផង និងបំណុលអ្នកស្រីគួន ណារី ផង ដែលប្តីប្រពន្ធនេះ មានកាតព្វកិច្ចត្រូវសង បំណុលទៅដើមចោទ និងចុងចម្លើយ ហើយក៏ពុំមានភស្តុតាងណាបញ្ជាក់ថា ប្តីប្រពន្ធនេះបានលែងលះគ្នាទេ ។

-យល់ឃើញថា ដើមចោទបានទទួលលិខិតបង្គាប់ឱ្យធ្វើសារណា និងបានទទួលដីកាកោះ ហើយប៉ុន្តែពុំបានធ្វើសារណា និងពុំបានមកចូលរួមនាសវនាការនេះទេ ដូច្នេះតុលាការកំពូល ជំនុំជំរះកំបាំងមុខ ចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៦៩(ច) ចុះថ្ងៃទី០៨-១០-២០០១ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈខុសឆ្គងទាំងទម្រង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខចុងចម្លើយ កំបាំងមុខដើមចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខ

១-ទទួលបណ្តឹងសាទុក្ខលេខ៣៥៤ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០១ របស់អ្នកស្រីអផទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៦៩(ច)ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០១របស់ សាលាឧទ្ធរណ៍ទាំងមូល ។

៣-រឹបអូសតូបលេខ១៤ នៅផ្សារចាស់ លក់ឡាយឡុង យកប្រាក់សងដើមចោទ និងចុងចម្លើយ តាមសមាមាត្រនៃបំណុល ។ បើតូបនេះមានតម្លៃលើសពីប្រាក់បំណុល ប្រាក់លើសនេះត្រូវ បានជាប្រយោជន៍ទៅអ្នកស្រីគួន ណារី ដែលមានអាទិភាព ។ ប៉ុន្តែបើអ្នកស្រីគួន ណារី ស្ម័គ្រ ចិត្តចង់បានតូបនេះ ដោយមិនបាច់លក់ឡាយឡុង អ្នកស្រីត្រូវចេញប្រាក់១៥០០ ដុល្លាអាមេរិក ដែលម្ចាស់តូបនៅជំពាក់ដើមចោទ សងទៅដើមចោទ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីដែលចុងចម្លើយបានបង់ជួសនៅតុលាការកំពូលចំនួន១៩.០០០រគឺៈ

-ពន្ធចុះបញ្ជីក្តីនិងពន្ធហ្នឹងចំនួន៤.០០០រប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រសម្រាប់ជារង្វាត់ក្រឡាបញ្ជីភាន់ហិបប្រាក់

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រ សរុប១៩.០០០រៀល ។

៥-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៤ ។